# ម្ដាយបានប្រាប់ខ្ញុំ

*អែលឌើរ ប្រេនលី ឌី ហ្វូសធ័រ*
*នៃពួកចិតសិបនាក់*

ព្រះអម្ចាស់បានដាក់មកលើឪពុកម្ដាយនូវការទទួលខុសត្រូវជាចំបង ក្នុងការចិញ្ចឹមបីបាច់ ដល់កូនចៅរបស់ពួកគេខាងវិញ្ញាណ។ នៅពេលខ្លះ ការទទួលខុសត្រូវនេះត្រូវបានដាក់មកលើឪពុក ឬម្ដាយទោល។ ម្ដាយរបស់ខ្ញុំផ្ទាល់ មានវ័យក្មេងណាស់ នៅពេលឪពុករបស់ខ្ញុំបានទទួលមរណភាព ដោយទុកឱ្យគាត់នៅជាមួយនឹងកូនបួននាក់តែម្នាក់ឯង។ ប៉ុន្តែគាត់បានប្រឈមមុខនឹងភាពមិនអនុគ្រោះរបស់គាត់ ដោយសេចក្ដីជំនឿ និងភាពក្លាហាន ដែលបានសន្យានឹងយើងថា បើសិនជាយើងស្ថិតនៅលើ ផ្លូវនៃសេចក្ដីពិត នោះទីផ្កាច់ព្រាត់នឹងបានល្អប្រសើរជាជាងពេលចាប់ផ្ដើម។ ដូចជាកូនៗដទៃទៀត ដែលមានម្ដាយអង់អាចនៅក្នុងព្រះគម្ពីរមរមន «យើងខ្ញុំ [មិន] សង្ស័យសោះថា [ម្ដាយ] របស់យើងដឹងការណ៍នេះ» (អាលម៉ា 56:48)។ បងប្អូនប្រុសស្រី ខ្ញុំយល់តាមរបៀបផ្ទាល់ខ្លួនមួយអំពីឥទ្ធិពលដ៏អស្ចារ្យរបស់ម្ដាយ។

មិត្តល្អរបស់ខ្ញុំ ឈ្មោះ ដន់ គៀសិន បានចែកចាយបទពិសោធន៍មួយ ដែលបង្ហាញអំពីឥទ្ធិពលនេះ។ នៅយប់មួយ កូនប្រុសអាយុបួនឆ្នាំរបស់គាត់ ឈ្មោះ អ៊ីរីក បានសុំឱ្យគាត់អានរឿងពេលចូលដេក។ អ៊ីរីក បានរើសសៀវភៅដែលវាស្រឡាញ់ចេញមកដែលមានឈ្មោះថា៖ ដំណើរផ្សងព្រេងរបស់ បេឌឌី ភ័គ ជារឿងមួយដែលនិយាយអំពីគ្រួសារមួយ រស់នៅលើកោះ ហើយធ្វើដំណើរពីកោះមួយទៅកោះមួយទៀត តាមរយៈពោងបង្ហោះ។ វាគឺជាសៀវភៅរូបភាព ដែលគ្មានអក្សរទេ ដូច្នេះបងប្រុស គៀសិន បានបង្កើតពាក្យនៅក្នុងរឿងនោះ។ «បេឌឌី ជិះពោងបង្ហោះ។ ឥឡូវនេះគាត់ចុះនៅលើកោះមួយ។ គាត់បានបោះខ្សែទៅក្រៅពោង។» អ៊ីរីក បានបញ្ឈប់គាត់។ វាបាននិយាយថា «ប៉ា មិនមែនជាខ្សែទេ។ វាគឺជាខ្សែពួរមួយ »។

បងប្រុស គៀសិន មើលទៅ អ៊ីរីក ហើយងាកមកមើលរូបភាពក្នុងសៀវភៅ បន្ទាប់មកក៏និយាយបន្តថា៖ «បេឌឌី កំពុងតែចុះពីពោង ហើយឡើងចុះដើមឈើ។ អូ៎! អត់ទេ អាវធំរបស់គាត់ទាក់នឹងមែកឈើហើយ!»

អ៊ីរីក បានបញ្ឈប់គាត់ម្ដងទៀត។ «ប៉ា នោះមិនមែនជាអាវធំទេ។ វាជាអាវពាក់ពីក្រៅ ។»

ឥឡូវនេះ បងប្រុស គៀសិន មានចិត្តអល់អែក។ គាត់និយាយថា «អ៊ីរីក នៅក្នុងសៀវភៅនេះគ្មានអក្សរទេ វាគ្រាន់តែជារូបភាព។ តើហេតុអ្វីបានជាកូននៅនិយាយថាវាគឺជាអាវពាក់ពីក្រៅ?»
អ៊ីរីក បានឆ្លើយថា «ដោយសារតែម៉ាក់ប្រាប់ដល់ខ្ញុំថាជាអាវ»។

ឪពុករបស់គាត់បានបិទសៀវភៅ ហើយនិយាយថា «អ៊ីរីក តើកូនគិតថាជាមេគ្រួសារ ដែលមានសិទ្ធិអំណាចសំខាន់នៅក្នុងផ្ទះនេះ?»

ពេលនេះ អ៊ីរីក បានគិតដោយប្រុងប្រយ័ត្ន មុនពេលវាឆ្លើយថា «គឺជាប៉ា»។

បងប្រុស គៀសិន ញញឹមដាក់កូនរបស់គាត់។ នេះជាចម្លើយដ៏ត្រឹមត្រូវណាស់! គាត់សួរថា «តើកូនដឹងដោយរបៀបណា?»។

អ៊ីរីក បានឆ្លើយយ៉ាងលឿនថា «ម៉ាក់ប្រាប់ដល់ខ្ញុំ»។

ដូចជាប្រធាន ជេមស៍ អ៊ីហ្វោសធ៍ បានមានប្រសាសន៍ថា៖ «គ្មានអ្វីដែលល្អជាងម្ដាយនៅក្នុងពិភពលោកទាំងមូលនេះទេ។ ឥទ្ធិពលរបស់ម្ដាយនៅក្នុងជីវិតកូនរបស់គាត់ គឺមិនអាចគណនាបានឡើយ»។ (នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1993 ទំព័រ 44 ឬ Ensign ខែ ឧសភា ឆ្នាំ 1993 ទំព័រ 35)។

តាមរយៈគម្រោងរបស់ព្រះ ការចិញ្ចឹមបីបាច់ហាក់ដូចជា ជាចំណែកនៃកេមរតកខាងវិញ្ញាណ ដែលត្រូវបានផ្ដល់ទៅឱ្យស្ត្រី។ ខ្ញុំបានមើលឃើញមរតកនេះមាននៅក្នុងកូនស្រីរបស់ខ្ញុំ ហើយឥឡូវនេះ មាននៅក្នុងចៅស្រីរបស់ខ្ញុំ--- សូម្បីតែពីមុនពេលពួកគេចេះដើរ ពួកគេចង់លើក និងមើលថែតុក្កតា កូនក្រមុំជ័រតូចរបស់ពួកគេ។

នៅក្នុងជំនាញរបស់ខ្ញុំ ជាកសិករ និងជាអ្នកចញ្ចឹមសត្វ ខ្ញុំមានឱកាសល្អដើម្បីមើលរបៀប ដែលសេចក្ដីស្រឡាញ់ ពីធម្មជាតិរបស់ម្ដាយ បង្ហាញឱ្យឃើញដោយផ្ទាល់ពីធម្មជាតិ។ នៅរាល់និទាឃរដូវ យើងបានឃ្វាលហ្វូងគោ និងកូនគោទើបកើតទៅតាមទន្លេ ស្នេក រដ្ឋអៃដាហូ ជាកន្លែងដែលពួកវាស៊ីស្មៅ នៅតាមជើងភ្នំ រយៈពេលមួយខែ។ បន្ទាប់មក យើងប្រមូលពួកវាមកវិញ ហើយនាំពួកវាចុះមកតាមផ្លូវ ដែលនាំទៅក្រោល។ ចេញពីនោះមក ពួកវាត្រូវបានលើកដាក់ទៅក្នុងឡាន ដែលដឹកពួកវាទៅកាន់វាលស្មៅរដូវក្ដៅនៅម៉ុនតាណា។

នៅក្នុងថ្ងៃនិទាឃរដូវក្ដៅមួយ ខ្ញុំបានជួយកៀងសត្វ ដោយការជិះនៅតាមក្រោយហ្វូងគោ នៅពេលពួកវាដើរចុះតាមផ្លូវដី ឆ្ពោះទៅកាន់ក្រោល។ ការងាររបស់ខ្ញុំ គឺឃ្វាលហ្វូងគោណា ដែលវង្វេងនៅលើផ្លូវ។ ដោយសារតែដំណើរវាយឺតៗ នោះខ្ញុំមានឱកាសគិតបានខ្លះៗ។

ដោយសារតែវាក្ដៅខ្លាំងពេក នោះកូនគោតូចៗចេះតែរត់ចេញទៅរកដើមឈើ ដើម្បីជ្រកម្លប់។ គំនិតរបស់ខ្ញុំ បានគិតប្រៀបធៀបទៅនឹងពួកយុវវ័យនៃសាសនាចក្រ ដែលពេលខ្លះ ត្រូវបានរំខាននៅលើផ្លូវតូច និងត្រង់ចង្អៀត។ ខ្ញុំក៏បានគិតអំពីអ្នកទាំងឡាយ ដែលបានចាកចេញពីសាសនាចក្រ ឬដែលអាចមានអារម្មណ៍ថា សាសនាចក្របានទុកពួកគេចោល ខណៈពេលដែលពួកគេត្រូវបានរំខាន។ ខ្ញុំបានគិតក្នុងខ្លួន

ឯងថា ការរំខានមួយ មិនចាំបាច់ថា ជាអំពើអាក្រក់ទេ វាជាឥទ្ធិពល--- (បញ្ឈប់នៅទីនេះ) ពេលខ្លះ វាអាចគ្រាន់តែជាម្លប់ប៉ុណ្ណោះ។

បន្ទាប់ពីការប្រមូលហ្វូងកូនគោដែលវង្វេង និងដោយបែកញើសអស់រយៈពេលប៉ុន្មានម៉ោងមក ខ្ញុំបានស្រែកហៅកូនគោដោយម៉ូរម៉ៅថា «ទៅតាមមេឯងទៅ! មេឯងដឹងថាត្រូវទៅកន្លែងណាហើយ! មេឯងធ្លាប់ដើរតាមផ្លូវនេះពីមុនមកហើយ!» មេរបស់ពួកវា ដឹងថាពេលនេះផ្លូវក្តៅ និងដីហុយមែន តែនៅទីបំផុតនឹងបានល្អប្រសើរជាងពេលចាប់ផ្តើមនេះ។

នៅពេលដែលយើងបាននាំកូនគោចូលក្រោលហើយភ្លាម នោះយើងបានកត់ចំណាំឃើញថា គោចំនួនបីក្បាល បានរត់ទៅច្រកទ្វារដោយជ្រួលច្រាល។ ពួកវារកមិនឃើញកូនរបស់ពួកវា ហើយហាក់ដូចជាដឹងថា កូនរបស់វានៅខាងក្រោយលើផ្លូវត្រង់កន្លែងណាមួយហើយ។ ក្មេងឃ្វាលគោម្នាក់ បានសួរខ្ញុំថា តើយើងគួរធ្វើយ៉ាងណាទៅ។ ខ្ញុំបាននិយាយថា «ខ្ញុំហ៊ានភ្នាល់ថា ខ្ញុំដឹងកន្លែងកូនគោទាំងនោះនៅឯណាហើយ។ ប្រហែលជានៅកន្លះគីឡូដីពីនេះ មានគម្ពោធឈើ។ ខ្ញុំប្រាកដថា យើងនឹងរកពួកវាឃើញនៅទីនោះ»។

ប្រាកដណាស់ ដូចជាអ្វីដែលខ្ញុំនឹកសង្ស័យ យើងបានរកឃើញកូនគោដែលវង្វេងរបស់យើង កំពុងតែដេកនៅក្រោមម្លប់។ ការទៅដល់របស់យើង បានធ្វើឱ្យពួកវាភ្ញាក់ ហើយពួកគេមិនព្រមឱ្យយើងគៀងពួកវាទេ។ ពួកវាភ័យខ្លាច ពីព្រោះយើង មិនមែន ជាមេរបស់វា! កាលណាយើងកាន់តែព្យាយាមដេញពួកគេឱ្យទៅរកក្រោល នោះពួកវាកាន់តែចចេស នៅទីបំផុតខ្ញុំបាននិយាយទៅកាន់អ្នកឃ្វាលគោថា «ឱ្យខ្ញុំសូមទោសអ្នកទាំងអស់គ្នា ខ្ញុំចេះច្រើនជាងនេះ។ តោះយើងត្រឡប់ទៅវិញ ហើយនាំមេវាចេញពីក្រោលមក។ គោទាំងអស់នឹងមកទទួលកូនរបស់ពួកវា ហើយកូនគោនឹងធ្វើតាមមេរបស់វា»។ ខ្ញុំត្រូវ។ មេគោបានដឹងយ៉ាងច្បាស់ថាត្រូវរកកូនរបស់ពួកវានៅកន្លែងណា ហើយពួកវានាំកូនឱ្យត្រលប់មកក្រោល ដូចដែលខ្ញុំបានរំពឹងទុក។

បងប្អូនប្រុសស្រី នៅក្នុងពិភពលោកមួយ ដែលមនុស្សគ្រប់គ្នាទទួលបានសិទ្ធិសេរីភាព មនុស្សជាទីស្រឡាញ់មួយចំនួនរបស់យើង អាចត្រូវវង្វេងដោយមូលហេតុណាមួយ។ ប៉ុន្តែយើងមិនអាចចុះចាញ់បានទេ។  យើងត្រូវតែត្រឡប់ទៅរកពួកគេជានិច្ច--- យើងមិនត្រូវឈប់ព្យាយាមនោះទេ។ ព្យាការីរបស់យើង ប្រធាន ថូម៉ាស អេស ម៉នសុន បានអង្វរដល់យើងឱ្យទៅជួយសង្គ្រោះអ្នកទាំងឡាយដែលជាទីស្រឡាញ់របស់យើង ដែលអាចនឹងត្រូវវង្វេង។ ដោយមានជំនួយរបស់ពួកអ្នកដឹកនាំបព្វជិតភាព នោះឪពុកម្តាយត្រូវតែបន្តត្រឡប់ទៅវិញ ហើយស្វែងរកមនុស្សដែលវង្វេងរបស់ពួកគេ ដោយអះអាងនឹងពួកគេថា នឹងមាន «គេហដ្ឋាន» មួយ ដែលមានគ្រួសារ សាសនាចក្រ នៅរង់ចាំពួកគេឱ្យត្រឡប់មកវិញជានិច្ច។ យើងមិនដឹងថាដួងចិត្តអាចនឹងត្រូវផ្លាស់ប្តូរនៅពេលណានោះទេ។ យើងមិនដឹងថា ព្រលឹងមួយ

អាចនឹងទន់ខ្សោយ ហើយសឹករិចរិលដោយលោកិយនៅពេលណានោះទេ។ នៅពេល... រឿងនោះកើតឡើង វាហាក់ដូចជាកូនចៅរបស់យើងស្ទើរតែទាំងអស់ តែងតែមករកម្ដាយមុនគេ ជាមួយនឹងអារម្មណ៍ដូចជាអ្នកទាំងឡាយណា ដែលបានបង្ហាញនៅក្នុងកំណាព្យមួយ ដោយ អេលីស្សាប៉ែត អាឃើស៍ ថា៖

> ថយក្រោយ ថយក្រោយ ឱ!ឆ្នាំដ៏ទុក្ខសោកដែលបានកន្លងហួស
> ខ្ញុំនឿយហត់ណាស់ដើម្បីពុះពារ និងមានទុក្ខវេទនា....
> នឿយហត់នឹងភាពទទេស្អាត ភាពអន់ថយ និងមិនពិត
> ឱ! ម៉ែអើយ ម៉ែ បេះដូងកូនហៅរកម៉ែ!
> នៅក្នុងថ្ងៃដែលបានកន្លងផុតទៅ ក្នុងដួងចិត្តកូន
> គ្មានសេចក្ដីស្រឡាញ់ណាធ្លាប់បង្ហាញដូចជាម៉ែនោះទេ
> គ្មានអ្វីធ្វើឱ្យភ្លេចការឈឺចាប់ ដូចជាក្ដីស្រឡាញ់របស់ម៉ែសម្រាប់កូន
> ចាប់តាំងពីព្រលឹងឈឺចាប់ និងខួរក្បាលដ៏នឿយហត់។
> ភាពទន់ភ្លន់បំពេរឱ្យកូនដេក
> យោលកូនឱ្យដេក ម៉ែអើយ យោលកូនឱ្យដេកលក់
>
> (សូមបំពេរខ្ញុំឲ្យដេកលក់ បណ្ណាល័យកំណាព្យគ្រួសារ និងចំរៀង បានបោះពុម្ពផ្សាយដោយ William Cullen Bryant [ឆ្នាំ 1870], 191 វណ្ណយុត្តិធ្វើឱ្យមានលក្ខណៈទំនើប)។

ប្រហែលជា មូលហេតុដែលយើងឆ្លើយតបជាសាកលបំផុតចំពោះសេចក្ដីស្រឡាញ់របស់ម្ដាយយើង គឺដោយសារតែវាជាសេចក្ដីស្រឡាញ់បែបព្រះអង្គសង្គ្រោះរបស់យើង។ ដូចជាប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានមានប្រសាសន៍ថា «សេចក្ដីស្រឡាញ់របស់ម្ដាយពិត កើតចេញមកស្ទើរតែដូចជាសេចក្ដីស្រឡាញ់របស់ព្រះ លើសជាងសេចក្ដីស្រឡាញ់ប្រភេទផ្សេងៗទៀត»។ («សេចក្ដីស្រឡាញ់របស់ម្ដាយ» Improvement Era ខែ មករា ឆ្នាំ 1910, 278)។

នៅក្នុងរឿងគ្រប់យ៉ាង ព្រះអង្គសង្គ្រោះបានធ្វើជាគំរូដ៏ល្អឥតខ្ចោះ នៅក្នុងសេចក្ដីស្រឡាញ់ ដែលទ្រង់បានបង្ហាញដល់ម្ដាយនៅលើផែនដីរបស់ទ្រង់។ សូម្បីតែនៅក្នុងខណៈពេលចុងក្រោយ នៃជីវិតរមែងស្លាប់របស់ទ្រង់--- បន្ទាប់ពីការរងទុក្ខនៅគេតសេម៉ានី ការកាត់ទោសចំអក ការពាក់មកុដបន្លា និងការឆ្កាងឈើឆ្កាងដ៏ធ្ងន់ដោយដំដែកគោលយ៉ាងព្រៃផ្សៃយ៉ាងណាក្ដី--- នៅក្នុងពេលដ៏សំខាន់បំផុត ក្នុងសាកលលោកនេះ ព្រះយេស៊ូវបានទតមើលម្ដាយរបស់ទ្រង់ពីលើឈើឆ្កាង ដែលជាម៉ារា នោះទង្វើនៃសេចក្ដីស្រឡាញ់ចុងក្រោយរបស់ទ្រង់ មុនពេលទ្រង់សុគត គឺត្រូវប្រាកដថា ម្ដាយរបស់ទ្រង់ នឹងត្រូវបានមើលថៃ ដោយមានបន្ទូលទៅកាន់យ៉ូហានជាសិស្សរបស់ទ្រង់ថា «នុះហ្ន៎! ម្ដាយអ្នក» (យ៉ូហាន 19:27) ហើយចាត់ពីពេលនោះមក សិស្សបាននាំគាត់ទៅផ្ទះ។ បន្ទាប់មកព្រះយេស៊ូវបានដឹងថា «ការទាំងអស់បានសម្រេចហើយ»

ហើយទ្រង់បានឱនព្រះសិរិសាររបស់ទ្រង់ រួចសុគតទៅ (សូមមើល យ៉ូហាន 19:28-30)។

នៅថ្ងៃនេះ ខ្ញុំឈរនៅចំពោះអ្នករាល់គ្នា ដើម្បីថ្លែងទីបន្ទាល់របស់ខ្ញុំថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះនៃពិភពលោក។ នេះគឺជាសាសនាចកក្ររបស់ទ្រង់ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ ព្រះវរបិតាសួគ៌របស់យើង សព្វព្រះទ័យចង់ឱ្យកូនចៅរបស់ទ្រង់ទាំងអស់ត្រឡប់មកកាន់ទ្រង់វិញ។ ខ្ញុំដឹងរឿងនេះដោយគ្មានការជំទាស់ឡើយ ដោយសារតែសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងដួងចិត្តរបស់ខ្ញុំ។ ជានិច្ចជាកាល ខ្ញុំមិនដឹងថា--- នៅពេលខ្ញុំនៅតូច ខ្ញុំត្រូវតែពឹងផ្អែកទៅលើទីបន្ទាល់ របស់ឪពុកម្ដាយរបស់ខ្ញុំទេ។ ម្ដាយរបស់ខ្ញុំធានាដល់ខ្ញុំថា បើសិនជាខ្ញុំស្ថិតនៅលើផ្លូវនៃសេចក្ដីពិត ទោះជានៅពេលដែលវាក្ដៅ ឬជីហុយ ទោះជានៅពេលមានការរំខានយ៉ាងណាក្ដី នោះនៅទីផ្ដាច់ព្រាត់ នឹងបានល្អប្រសើរជាងពេលចាប់ផ្ដើមនេះ។ ខ្ញុំមានអំណរគុណដ៏អស់កល្បជានិច្ចដែលម្ដាយរបស់ខ្ញុំបានប្រាប់ដល់ខ្ញុំ។

នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។